ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ....៣១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគទីតាំងដី និងអគាររបស់មន្ទីរអង្គភាព ជុំវិញខេត្តសៀមរាប នៅក្នុងស្រុកសៀមរាប ខេត្តសៀមរាប

~~~~~~~~~~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងតាមការចាំបាច់

## សម្រេច

**មាត្រា១.-**

ត្រូវបានធ្វើអនុបយោគទីតាំងដី និងអាគាររបស់មន្ទីរអង្គភាពជុំវិញខេត្តសៀមរាប ទំហំ ១១០.៩៩៥,៣៩ ម៉ែត្រក្រឡា (មួយរយដប់ពាន់ប្រាំរយហាសិបប្រាំម៉ែត្រក្រឡា និងសាមសិបប្រាំបួន )ស្ថិតនៅក្នុងស្រុកសៀមរាប ខេត្តសៀមរាប ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រួមមានទីតាំង និងទំហំដីមន្ទីរអង្គភាពនីមួយៗ ដូចតទៅ :
~~~~~~~~~~

ឯកតា គិតជាម៉ែត្រក្រឡា

| | |
|---|---|
| ១-ដី និងអគារ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ភូមិវត្តបូព៌ ឃុំសាលាកំរើក | ៨៥០,០០ ម$^{២}$ |
| និងដី និងអគារមន្ទីរភូមិវត្តបូព៌ ឃុំសាលាកំរើក | ៤៥៥,០០ ម$^{២}$ |
| ២-ដី និងអគារ មន្ទីរព័ត៌មាន មណ្ឌល១ ឃុំស្វាយដង្គំ (ផ្ទះល្វែង) | ១០៤,០០ ម$^{២}$ |
| និងដី និងអគារការិយាល័យវិទ្យុ មណ្ឌល១ ឃុំស្វាយដង្គំ (ផ្ទះល្វែង) | ១៣៦,០០ ម$^{២}$ |
| ៣-ដី និងអគារ មន្ទីរសុខាភិបាលមណ្ឌល១ ឃុំស្វាយដង្គំ (ផ្ទះល្វែង) | ៣៣៤,០០ ម$^{២}$ |
| ៤-ដី និងអគារ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ភូមិវត្តបូព៌ ឃុំសាលាកំរើក | ៧០៣,៦៨ ម$^{២}$ |
| ៥-ដី និងអគារ មន្ទីរពាណិជ្ជកម្ម ភូមិវត្តបូព៌ ឃុំសាលាកំរើក (ផ្ទះល្វែង) | ៣០៦,០០ ម$^{២}$ |
| និងដី និងអគារមន្ទីរ មណ្ឌល១ ឃុំស្វាយដង្គំ (ផ្ទះល្វែង) | ៥៦,០០ ម$^{២}$ |
| ៦-ដី និងអគារ មន្ទីរអប់រំ យុវជន និងកីឡា ភូមិស្ទឹងថ្មី ឃុំស្វាយដង្គំ | ១៤.០០០,០០ ម$^{២}$ |
| និងដីអតីតរោងចក្រអារឈើ ភូមិបន្ទាយចាស់ ឃុំស្លក្រាម | ១០.០០០,០០ ម$^{២}$ |
| ៧-ដី និងអគារការិយាល័យជលផល ភូមិវត្តបូព៌ ឃុំសាលាកំរើក | ១.២៨៨,០០ ម$^{២}$ |
| -ដី និង ឃ្លាំងសំភារៈ ភូមិវត្តបូព៌ ឃុំសាលាកំរើក | ២.៣៣៨,០០ ម$^{២}$ |
| -ដី និងអគារការិយាល័យរុក្ខាប្រមាញ់(រដ្ឋបាលព្រៃឈើ) ភូមិវត្តដំណាក់ ឃុំសាលាកំរើក | ២.៩៣៣,០០ ម$^{២}$ |
| ៨-ដី និងអគារ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ភូមិវត្តបូព៌ ឃុំសាលាកំរើក | ១.៤៦៦,០០ ម$^{២}$ |
| ៩-ដី និងអគារ មន្ទីរបរិស្ថាន មណ្ឌល១ ឃុំស្វាយដង្គំ | ១.៦៧៦,០០ ម$^{២}$ |
| ១០-ដី និងអគារ មន្ទីរអភិវឌ្ឍន៍ជនបទ មណ្ឌល១ ឃុំស្វាយដង្គំ | ៦.៥២០,០០ ម$^{២}$ |
| ១១-ដី និងអគារ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មណ្ឌល១ ឃុំស្វាយដង្គំ | ២.២០៣,១៥ ម$^{២}$ |
| ១២-ដី និងអគារ មន្ទីរធម្មការ និងសាសនា មណ្ឌល១ ឃុំស្វាយដង្គំ (ផ្ទះល្វែង) | ៣៩,៥៦ ម$^{២}$ |
| ១៣-ដី និងអគារ មន្ទីរកិច្ចការនារី មណ្ឌល១ ឃុំស្វាយដង្គំ | ៣.៣៧០,០០ ម$^{២}$ |
| ១៤-ដី និងអគារ មន្ទីរសាធារណការ និងដឹកជញ្ជូន ភូមិវត្តបូព៌ ឃុំសាលាកំរើក | ៣.៣២៥,០០ ម$^{២}$ |
| ១៥-ដី និងអគារ មន្ទីរទេសចរណ៍ ភូមិស្លក្រាម ឃុំស្លក្រាម | ៤.៣២៨,០០ ម$^{២}$ |
| ១៦-ដី និងអគារ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មណ្ឌល១ ឃុំស្វាយដង្គំ | ២.០៥៨,០០ ម$^{២}$ |
| ១៧-ដី និងអគារ មន្ទីរធនធានទឹក និងឧតុនិយម ភូមិកសិកម្ម ឃុំស្រង៉ែ | ៣៩.៨២៥,០០ ម$^{២}$ |
| ១៨-ដី និងអគារសាលាខេត្ត មណ្ឌល១ ឃុំស្វាយដង្គំ | ៥.៥៤០,០០ ម$^{២}$ |
| -ដី និងអគារសាលាខេត្ត មណ្ឌល១ ឃុំស្វាយដង្គំ | ១.៣២៧,០០ ម$^{២}$ |
| -ដីសាលាខេត្ត មណ្ឌល២ ឃុំស្វាយដង្គំ | ១.៥០០,០០ ម$^{២}$ |
| ១៩-ដី និងអគារ រតនាគារ មណ្ឌល១ ឃុំស្វាយដង្គំ | ២.៦០១,០០ ម$^{២}$ |
| ២០-ដី និងអគារ សាខាពន្ធដារ ភូមិសាលាកន្សែង ឃុំស្វាយដង្គំ | ៨៧៣,០០ ម$^{២}$ |
| **សរុបទំហំផ្ទៃដី** (មួយរយដប់ពាន់ប្រាំរយហាសិបប្រាំម៉ែត្រក្រឡា និងសាមសិបប្រាំបួន) | **១១០.៥៥៥,៣៩ ម$^{២}$** |

**មាត្រា២.-**

ត្រូវបានដូរទីតាំងដី និងអគាររបស់មន្ទីរអង្គភាពជុំវិញខេត្តសៀមរាប ទំហំ ១១០.៥៥៥,៣៩ ម៉ែត្រក្រឡា ( មួយរយដប់ពាន់ប្រាំរយហាសិបប្រាំម៉ែត្រក្រឡា និងសាមសិបប្រាំបួន ) ស្ថិតនៅក្នុងស្រុកសៀមរាប ខេត្តសៀមរាប ដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ មកទីតាំងដី និងអាគារថ្មី ស្ថិតនៅក្នុងមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាប លើផ្ទៃដីទំហំ ៤០ (សែសិប) ហិកតា ។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មេសា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

-ដូចមាត្រា ៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ